សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management

# ប្រព័ន្ធគតិយុត្តិអាស៊ាន

Www.KhmerFamous.Com

# ប្រព័ន្ធគតិយុត្តអាស៊ាន

១.កំនត់បង្ហាញអំពីរចនាសម្ព័ន្ធអាស៊ានៈ *(សំខាន់)*

- អង្គការចាត់តាំង (កិច្ចប្រជុំអាស៊ាន)
- ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន
- ក្រុមប្រឹក្សាសហគមន៍អាស៊ាន
- អង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញតាមផ្នែករបស់អាស៊ាន
- អគ្គលេខាធិការអាស៊ាន និងលេខាធិការដ្ឋានអាស៊ាន
- តំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន
- លេខាធិការដ្ឋានជាតិអាស៊ាន
- គ្រឹះស្ថានអាស៊ាន
- អង្គភាពចំណុះអាស៊ាន

២. សិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋសមាជិកអាស៊ាន *(សំខាន់)*

- ក្រោមធម្មនុញ្ញអាស៊ាន រដ្ឋសមាជិកអាស៊ានទាំងអស់មានសិទ្ធិនិងកាតព្វកិច្ចស្មើគ្នា។
- រដ្ឋសមាជិកត្រូវចាត់គ្រប់វិធានការចាំបាច់រួមមានទាំងការអនុម័តច្បាប់ក្នុងស្រុករបស់ខ្លួនអោយមានលក្ខណៈសមស្របដើម្បីអនុវត្តដោយមានប្រសិទ្ធភាព នូវបទបញ្ញត្តិនៃធម្មនុញ្ញនេះនិងអោយបានសមស្របគ្រប់កាតព្វកិច្ចនៃសមាជិកភាព។
- ក្នុងករណីដែលមានការរំលោភធ្ងន់ធ្ងរ ឬមិនគោរពតាមធម្មនុញ្ញអាស៊ាន នឹងត្រូវអនុវត្តតាមមាត្រា ២០។

៣.អាស៊ានមានដៃគូសន្ទនាក្រៅតំបន់ដូចជាៈ *(សំខាន់)*

- អាស៊ាន+១ៈ ប្រទេសអាស៊ានទាំង ១០ បូកនឹងប្រទេសឥណ្ឌា
- អាស៊ាន ជាមួយនឹងដៃគូសន្ទនា អាមេរិក
- អាស៊ាន ជាមួយនឹងដៃគូសន្ទនា កាណាដា
- អាស៊ាន ជាមួយនឹងដៃគូសន្ទនា អូស្ត្រាលី
- អាស៊ាន+៣ មានន័យថាប្រទេសអាស៊ានទាំង ១០ បូកនឹងប្រទេសចិន កូរ៉េនិងជប៉ុន។
- អាស៊ាន+EURPEមានន័យថាប្រទេសអាស៊ានទាំង ១០ បូកនឹងអឺរ៉ុប។
- អាស៊ាន+មជ្ឈឹមបូព៌ាមានន័យថាប្រទេសអាស៊ានទាំង ១០ បូកនឹងប្រទេសមជ្ឈឹមបូព៌ា។
- អាស៊ាន ជាមួយនឹងដៃគូសន្ទនា ៨ ប្រទេសផ្សេងទៀតដែលមាន សក្តានុពលខាងយោធា រួមមាន ចិន កូរ៉េខាងត្បូង ជប៉ុន ឥណ្ឌា រុស្ស៊ី អូស្ត្រាលី កាណាដា និងសហរដ្ឋអាមេរិក។

៤. បង្ហាញពីយន្តការដោះស្រាយជំលោះអាស៊ានៈ *(សំខាន់)*

- ❖ យន្តការដោះស្រាយតាមគោលការណ៍ទូទៅ
    - (a) រដ្ឋសមាជិកអាស៊ានត្រូវខិតខំប្រឹងប្រែងដោះស្រាយជំលោះទាំងឡាយដោយសន្តិវិធីអោយទាន់ ពេលវេលាតាមរយៈកិច្ចសន្ទនា ការប្រឹក្សាយោបល់និងការចរចារ។

(b) អាស៊ានត្រូវរក្សានិងបង្កើតយន្តការដោះស្រាយជំលោះលើគ្រប់វិស័យនៃកិច្ចសហប្រតិបត្តិការរបស់ខ្លួន។

❖ យន្តការដោះស្រាយជំលោះតាមរយៈអន្តរការី និងការនាំសំរុះសំរួល

(a) រដ្ឋសមាជិកដែលជាភាគីនៃជំលោះអាចព្រមព្រៀងគ្នា នៅពេលណាមួយក្នុងការស្វែងរកមធ្យោ បាយដោះស្រាយវិវាទតាមរយៈអន្តរការីការផ្សះផ្សាឬការសំរុះសំរួលក្នុងពេលវេលាជាក់លាក់ដែលបានព្រមព្រៀងគ្នា។

(b) ភាគីក្នុងជំលោះអាចស្នើសុំប្រធានអាស៊ានឬអគ្គលេខាធិការអាស៊ានក្នុងតួនាទីជា មន្ត្រីផ្លូវការដើម្បីផ្តល់នូវអន្តរការី ការផ្សះផ្សាឬការនាំសំរុះសំរួល។

❖ យន្តការដោះស្រាយជំលោះក្នុងលិខិតូបករណ៍ពិសេស

(a) រាល់ជំលោះដែលទាក់ទងនឹងលិខិតូបករណ៍ពិសេសរបស់អាស៊ានត្រូវដោះស្រាយតាមរយៈយន្តការ និងនីតិវិធីដែលមានចែងក្នុងលិខិតូបករណ៍ទាំងនោះ។

(b) ចំពោះជំលោះដែលមិនពាក់ព័ន្ធនឹងការបកស្រាយឬការអនុវត្តន៍តាមលិខិតូបករណ៍អាស៊ានណាមួយ ត្រូវដោះស្រាយដោយសន្តិវិធីដោយអនុលោមតាមសន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅ អាស៊ីអាគ្នេយ៍ (TAC) និងវិធាននៃនីតិវិធីរបស់សន្ធិសញ្ញានេះ។

(c) ប្រសិនបើមិនមានបញ្ញត្តិផ្សេងពីនេះទេជំលោះដែលពាក់ព័ន្ធនឹងការបកស្រាយឬការអនុវត្តន៍កិច្ចព្រម ព្រៀងសេដ្ឋកិច្ចអាស៊ានត្រូវដោះស្រាយទៅតាមពិធីសារអាស៊ានស្តីពីយន្តការពង្រឹងការដោះស្រាយ ជំលោះ។

❖ ការបង្កើតយន្តការដោះស្រាយជំលោះ

ប្រសិនបើពុំមានបញ្ញត្តិផ្ទុយពីយន្តការដោះស្រាយជំលោះសមស្របដែលរួមទាំងមជ្ឈត្តវិនិច្ឆ័យនិងត្រូវ បង្កើតឡើងសំរាប់ជំលោះដែលពាក់ព័ន្ធដល់ការបកស្រាយឬការអនុវត្តន៍ធម្មនុញ្ញនេះនិងលិខិតូបករណ៍អាស៊ានដទៃទៀត។

❖ ជំលោះដែលមិនអាចដោះស្រាយបាន

ក្នុងករណីដែលជំលោះនៅតែមិនអាចដោះស្រាយបានបន្តបន្ទាប់ពីអនុវត្តតាមបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិខាងលើ ជំលោះត្រូវដាក់ជូនកិច្ចប្រជុំអាស៊ានដើម្បីធ្វើសេចក្តីសំរេច។

❖ អំពីការប្រតិបត្តិ

(a) អគ្គលេខាធិការអាស៊ានដែលជួយជ្រោមជ្រែងពីលេខាធិការដ្ឋានអាស៊ានឬអង្គភាពអាស៊ានដែលមាន ការតែងតាំងណាមួយត្រូវត្រួតពិនិត្យការប្រតិបត្តិតាមភស្តុតាងជាក់ស្តែងអនុសាសន៍ឬសេចក្តីសំរេច ដែលចេញពីយន្តការដោះស្រាយជំលោះអាស៊ានហើយត្រូវផ្តល់របាយការណ៍នេះជូនកិច្ចប្រជុំអាស៊ាន ជ្រាប។

(b) រដ្ឋសមាជិកណាមួយដែលរងផលប៉ះពាល់ដោយសារការមិនគោរពទៅតាមភស្តុតាងជាក់ស្តែងឬអនុ សាសន៍ឬសេចក្តីសំរេច ចេញពីយន្តការដោះស្រាយជំលោះ អាចដាក់បញ្ហានេះជូនកិច្ចប្រជុំកំពូល អាស៊ានដើម្បីធ្វើសេចក្តីសំរេច។

៥.លើកបង្ហាញពីការបង្កើត និងតួនាទីរបស់គណៈកម្មាធិការអចិន្ត្រៃអាស៊ាន

❖ ការបង្កើតគណៈកម្មាធិការអចិន្ត្រៃ

- រដ្ឋសមាជិកអាស៊ាននីមួយៗ ត្រូវតែងតាំតំណាងអចិន្ត្រៃរបស់ខ្លួនមួយរូប ប្រចាំអាស៊ានដែលមានឋានៈជាឯកអគ្គរដ្ឋទូតឬឯករដ្ឋទូតមានទីតាំងនៅ ទីក្រុងហ្សាការតា។

- ❖ តួនាទីរបស់គណៈកម្មាធិការអចិន្ត្រៃអាស៊ាន
  - ទ្រទ្រង់ការងារក្រុមប្រឹក្សាសហគមន៍អាស៊ាននិងអង្គភាពថ្នាក់រដ្ឋមន្ត្រីជំនាញអាស៊ានតាមផ្នែក។
  - សំរបសំរួលជាមួយលេខាធិការដ្ឋានជាតិអាស៊ាននិងអង្គភាពថ្នាក់រដ្ឋមន្ត្រី ជំនាញតាមផ្នែកដទៃទៀត របស់អាស៊ាន។
  - ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអគ្គលេខាធិការអាស៊ាន និងលេខាធិការដ្ឋាន អាស៊ានលើគ្រប់វិស័យពាក់ព័ន្ធទាំងឡាយដល់ការងាររបស់ខ្លួន។
  - សំរបសំរួលសហប្រតិបត្តិការរបស់អាស៊ានជាមួយដៃគូក្រៅតំបន់។
  - បំពេញការងារដទៃទៀតដែលអាចកំណត់ឡើងដោយ ក្រុមប្រឹក្សាសំរប-សំរួលអាស៊ាន។

៦.នីតិវិធី តែងតាំង និងអាណត្តិរបស់អគ្គលេខាធិការនិងអគ្គលេខាធិការរងអាស៊ានៈ

- ❖ ការតែងតាំង និងអាណត្តិរបស់អគ្គលេខាធិការអាស៊ាន១រូប
  - ត្រូវបានស្នើសុំដោយក្រុមប្រឹក្សាសម្របសម្រួល
  - ត្រូវបានតែងតាំងដោយកិច្ចប្រជុំអាស៊ាន។
  - ត្រូវបានរើសចេញពីក្នុងចំណោមជនជាតិនៃរដ្ឋសមាជិកអាស៊ានដោយប្តូរវេនគ្នាតាមលំដាប់អក្សរក្រមនៃឈ្មោះរដ្ឋសមាជិក ហើយត្រូវបានពិចារណាល្អិតល្អន់ទៅលើសុចរិតធម៌ សមត្ថភាព បទពិសោធវិជ្ជាជីវៈ និងសមភាពជេនឌ័រ។
  - មានអាណត្តិ៥ឆ្នាំ។
  - អាណត្តិនេះមិនអាចបន្តបានទេ។
- ❖ ការតែងតាំង និងអាណត្តិរបស់អគ្គលេខាធិការរងអាស៊ាន៤រូប(មានសញ្ជាតិខុសពីអគ្គលេខាធិការនិងមកពីរដ្ឋ ទាំងបួនខុសផ្សេងគ្នា)
  - អគ្គលេខាធិការស្នើសុំទៅក្រុមប្រឹក្សាសម្របសម្រួលតែងតាំងអគ្គលេខាធិការរង។ បន្ទាប់មកក្រុមប្រឹក្សាសម្របសម្រួលស្នើសុំទៅកិច្ចប្រជុំអាស៊ានតែងតែងអគ្គលេខាធិការរងនោះ។
  - កិច្ចប្រជុំអាស៊ានតែងតាំងអគ្គលេខាធិការរង
  - អគ្គលេខាធិការរងទាំង៤រូបមានអាណត្តិដូចតទៅៈ
    - ▪ អគ្គលេខាធិការរង២រូបមានអាណត្តិ៣ឆ្នាំដែលមិនអាចបន្តបាន។ ជ្រើសចេញពីជនជាតិនៃរដ្ឋជាសមាជិកអាស៊ានដោយប្តូរវេនគ្នាតាម លំដាប់អក្សរក្រមនិងដោយពិចារណាលើ សុចរិតធម៌ គុណសម្បត្តិ សមត្ថភាព បទពិសោធន៍ និងសមភាពជេនឌ័រ។
    - ▪ អគ្គលេខាធិការរង២រូបមានអាណត្តិ៣ឆ្នាំ អាចបន្តបានមួយអាណត្តិទៀត។ ជ្រើសជាចំហាដោយផ្អែកទៅលើលក្ខណៈសម្បត្តិដែលសម នឹងទទួលបានតួនាទីនេះ។

៧.បញ្ញាញពីៈ

ក.បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អគ្គលេខាធិការអាស៊ាននិងមន្ត្រីអាស៊ាន(ម១៨ ២០វិច្ឆកា២០០៧)

- ❖ អគ្គលេខាធិការអាស៊ាននិងបុគ្គលិកនៃលេខាធិការដ្ឋានអាស៊ានដែលចូលរួមក្នុងសកម្មភាព ជាផ្លូវការរបស់អាស៊ាន ឬជាតំណាងអាស៊ានប្រចាំរដ្ឋសមាជិកចាំបាច់ត្រូវបានទទួលបុព្វ សិទ្ធិដើម្បីបំពេញមុខនាទីរបស់ខ្លួនដោយ ឯករាជ្យ។
- ❖ បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិដែលមានចែងក្នុងមាត្រានេះត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀង ដោយឡែកមួយទៀតរបស់អាស៊ាន។

ខ. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តំណាងអចិន្ត្រៃនិងមន្ត្រីដែលកំពុងបំពេញភារកិច្ចនៅអាស៊ាន

- តំណាងអចិន្ត្រៃយ៍របស់រដ្ឋសមាជិកប្រចាំនៅអាស៊ាននិងមន្ត្រីរបស់រដ្ឋសមាជិកដែលចូលនរួមក្នុងសកម្មភាពជាផ្លូវការការរបស់អាស៊ានឬដែលជាតំណាងអាស៊ានប្រចាំរដ្ឋសមាជិក ចាំបាច់ត្រូវទទួលបានបុព្វសិទ្ធិនិង អភ័យឯកសិទ្ធិដើម្បីបំពេញមុខនាទីរបស់ខ្លួនដោយឯករាជ្យ។
- បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់តំណាងអចិន្ត្រៃយ៍និងមន្ត្រីដែលកំពុងបំពេញភារកិច្ចនៅអាស៊ានត្រូវស្ថិតនៅក្រោមអនុសញ្ញាទីក្រុងវីយែន ១៩៦១ ស្តីពីទំនាក់ទំនងការទូតឬអនុលោមទៅតាមច្បាប់ជាតិរបស់សមាជិក នីមួយៗ ។

៨.លក្ខខណ្ឌដើម្បីរដ្ឋមួយអាចចូលជាសមាជិកអាស៊ានៈ

- ទីតាំងភូមិសាស្ត្រដែលត្រូវបានទទួលស្គាល់ថាស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍
- មានការទទួលស្គាល់ពីបណ្តារដ្ឋសមាជិកអាស៊ានទាំងអស់
- ឯកភាពគោរពនិងប្រតិបត្តិតាមធម្មនុញ្ញអាស៊ាន
- មានលទ្ធភាព និងឆន្ទៈអនុវត្តកាតព្វកិច្ចទាំងអស់នៃសមាជិកភាព
- ការតំរូវថែមអោយមានការបង់វិភាគទាន១លានដុល្លារតែមួយដងនៅពេលចូលដំបូង និង បង់វិភាគទានមូលនិធិវិទ្យាសាស្ត្រចំនួន៥មឺនដុល្លារតែមួយដងគត់ហើយក៏ត្រូវមានចំណាយប្រចាំឆ្នាំចំនួន៦០មឺនដុល្លារដែរសំរាប់ដំណើរការអគ្គលេខាធិការដ្ឋានអាស៊ាន សំរួលទិដ្ឋិការចេញចូលដោយមិនបាច់ធ្វើពាក្យសុំជាពិសេសត្រូវដាក់ស្ថានទូតប្រចាំរដ្ឋជាសមាជិកអាស៊ានទាំងអស់។

៩.គោលនយោបាយការបរទេសក្នុងទំនាក់ទំនងអន្តរជាតិរបស់អាស៊ានៈ *(សំខាន់)*

- អាស៊ានត្រូវអភិវឌ្ឍទំនាក់ទំនងជាមិត្តភាពនិងកិច្ចសន្ទនាដែលផ្តល់ផលប្រយោជន៍ទៅវិញ ទៅមកក្នុងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូជាមួយបណ្តាប្រទេសនិងអនុតំបន់និងអង្គការអន្តរជាតិនិងស្ថាប័នដទៃទៀត។
- ទំនាក់ទំនងក្រៅតំបន់របស់អាស៊ានត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងឡាយដែលមាន ចែងក្នុងធម្មនុញ្ញអាស៊ាននេះ។
- អាស៊ានត្រូវតែជាកំលាំងនាំមុខជាចំបងមួយនៅក្នុងការរៀបចំតំបន់ដែល ខ្លួនផ្តួចផ្តើមនិង រក្សាភាពជាស្នូលរបស់ខ្លួនក្នុងកិច្ចសហប្រតិបត្តិការតំបន់របស់អាស៊ាន និងការកសាងសហគមន៍។
- ក្នុងការអនុវត្តន៍ទំនាក់ទំនងក្រៅតំបន់អាស៊ាន រដ្ឋសមាជិកត្រូវសម្របសម្រួល និងខិតខំ ប្រឹងប្រែងអភិវឌ្ឍជំហររួមនិងធ្វើសកម្មភាពរួមគ្នាលើមូលដ្ឋាននៃភាពឯកភាពនិងសាមគ្គីភាព។
- ទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រនៃទំនាក់ទំនងក្រៅតំបន់របស់អាស៊ាន ត្រូវដាក់ចេញដោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន។

- កិច្ចប្រជុំមន្ត្រីការបរទេសអាស៊ានត្រូវធានាអោយមានភាពស្របគ្នានិងភាពរលូនក្នុងការអនុវត្តទំនាក់ទំនងក្រៅតំបន់របស់អាស៊ាន។
- អាស៊ានអាចសំរេចកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសឬអនុតំបន់និងអង្គការអន្តរជាតិនិង ស្ថាប័នទាំងឡាយបាន។ នីតិវិធីនៃការសំរេចកិច្ចព្រមព្រៀងនេះត្រូវបញ្ញត្តិដោយក្រុមប្រឹក្សា សម្របសម្រួលអាស៊ានដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសហគមន៍អាស៊ាន។

១០.គណកម្មាធិការអាស៊ាននៅក្នុងប្រទេសទីបី និងអន្តរជាតិ៖ *(សំខាន់)*

- គណៈកម្មាធិការអាស៊ានក្នុងប្រទេសទី៣អាច ត្រូវបង្កើតឡើងនៅក្នុងប្រទេសពុំមែនជា សមាជិកអាស៊ានដែលក្នុងនោះមានប្រធានបេសកម្មការទូតនៃរដ្ឋសមាជិកអាស៊ាន។ គណៈកម្មាធិការនេះស្រដៀងគ្នាក៏អាចត្រូវបង្កើតឡើងដោយទាក់ទងទៅនឹងអង្គការអន្តរជាតិ។ គណៈកម្មាធិការនេះត្រូវលើកស្ទួយផលប្រយោជន៍និងអត្តសញ្ញាណអាស៊ាននៅក្នុងប្រ ទេសម្ចាស់ផ្ទះនិងអង្គការអន្តរជាតិ។
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសត្រូវកំណត់អំពីវិធាននីតិវិធីរបស់គណៈកម្មាធិការនេះ។

១១.សេចក្តីសំរេចរបស់អាស៊ាន *(សំខាន់)*

- **វិធានទូទៅ៖**
- ជាគោលការណ៍គ្រឹះ រាល់សេចក្តីសំរេចចិត្តរបស់អាស៊ាន ត្រូវឈរលើមូលដ្ឋាននៃការប្រឹក្សានិងកុងសង់ស៊ីស(១០/១០)
- ក្នុងករណីដែលមិនមានកុងសង់ស៊ីស កិច្ចប្រជុំកំពូលអាស៊ានអាចនឹងធ្វើការសំរេចអំពីរបៀបនៃការធ្វើសេចក្តី សំរេចចិត្តជាក់លាក់មួយ(៧/១០)។
- **វិធានដោយឡែក៖**
- ក្នុងករណីមានការរំលោភធ្ងន់ធ្ងរឬការប្រព្រឹត្តផ្ទុយទៅនឹងធម្មនុញ្ញនេះសេចក្តីសំរេចនេះត្រូវដាក់ជូនកិច្ចប្រជុំកំពូលអាស៊ាន។
- សេចក្តីសំរេចខ្លះតាមលិខិតូបករណ៍គតិយុត្តដែលពាក់ព័ន្ធរបស់អាស៊ានដទៃទៀត។

១២.បង្ហាញពីសារៈសំខាន់នៃលេខាធិការដ្ឋានជាតិអាស៊ាន៖

- ជាអង្គភាពអចិន្ត្រៃយ៍មួយឬជាអង្គភាពកណ្តាលដើម្បីធ្វើការសំរបសំរួល
- ជានានូវនិរន្តរភាពនៃការប្រព្រឹត្តទៅរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។

១៣.អ្នកសំរបសំរួលប្រទេសដៃគូសន្ទនាអាស៊ាន៖

- រដ្ឋសមាជិកដែលដើរតួនាទីជាប្រទេសសម្របសម្រួលប្តូរវេនគ្នា ទទួលខុសត្រូវក្នុងការសម្របសម្រួលនិងជុំវិញ ផលប្រយោជន៍អាស៊ានក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយដៃគូសន្ទនាពាក់ព័ន្ធនិងជាមួយអង្គការតំបន់និងជាមួយ អង្គការអន្តរជាតិ និងស្ថាប័នដទៃទៀត។
- ក្នុងទំនាក់ទំនងជាមួយដៃគូក្រៅតំបន់ប្រទេសសម្របសម្រួលត្រូវ៖
  - តំណាងអាស៊ានិងលើកកំពស់ទំនាក់ទំនងដោយឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមកនិងសមភាពស្របទៅតាមគោលការណ៍របស់អាស៊ាន។
  - ធ្វើជាសហប្រធានកិច្ចប្រជុំពាក់ព័ន្ធរវាងអាស៊ាននិងដៃគូក្រៅតំបន់។

- ○ គាំទ្រគណៈកម្មាធិការអាស៊ានពាក់ព័ន្ធនានានៅក្នុងប្រទេសទី៣និងនៅអង្គការអន្តរជាតិនានា។

១៩.បាវចនាអាស៊ានៈ "ចក្ខុវិស័យមួយ អត្តសញ្ញាណមួយសហគមន៍មួយ" ។